# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ...៤២...អនក្រ-បក

## អនុក្រឹត្យ
## ស្ដីពី
## ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៤០អនក្រ បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃសវនកម្មផ្ទៃក្នុង នៅតាមស្ថាប័នក្រសួង និងសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា១ :**

អនុក្រឹត្យនេះកំណត់ពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ ដោយអនុលោមទៅតាមច្បាប់ស្ដីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃសវនកម្មផ្ទៃក្នុង នៅតាមបណ្ដាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ ។

**មាត្រា២ :**

ត្រូវបានបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ ។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងជាស្ថាប័នចំណុះផ្ទាល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី២

## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រង

**មាត្រា៣ :**

នាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃជាសេនាធិការផ្ទាល់របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ មានសិទ្ធិពេញលេញ សេរីភាពគ្រប់គ្រាន់ គ្មានការហាមប្រាម គ្មានការរារាំងក្នុងការពិនិត្យឡើងវិញលើបញ្ជីកត់ត្រា,ចំណូលចំណាយថវិកា,ទ្រព្យសម្បត្តិ និង បញ្ជីបុគ្គលិករបស់អង្គភាពទាំងអស់ដែលស្ថិតក្រោមឱវាទក្រសួងមហាផ្ទៃ ។

**មាត្រា៤ :**

នាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃមានភារកិច្ចសំខាន់ៗដូចតទៅ :

- ធ្វើផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំឱ្យមានភាពសមស្របច្បាស់លាស់គ្រប់គ្រាន់ ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ពិនិត្យ និងសំរេច ។
- ពិនិត្យឡើងវិញលើការអនុវត្តច្បាប់ បទបញ្ជា វិន័យថវិកា និងអភិបាលកិច្ចល្អនៅក្នុងប្រតិបត្តិការ ហិរញ្ញវត្ថុ ពិសេសការកៀរគរ និងគ្រប់គ្រងចំណូល ការចំណាយ ថវិកាហិរញ្ញប្បទាន និងបំណុល ។
- ធ្វើការវាយតម្លៃផែនការ និង សកម្មភាពសវនកម្មផ្ទៃក្នុង ដែលបានចាត់ចែងកន្លងមក ។
- ធ្វើរបាយការណ៍ និង សេចក្តីសន្និដ្ឋាននៃសវនកម្មផ្ទៃក្នុងជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ផ្ញើជូនអាជ្ញាធរសវនកម្មជាតិ ។
- ពិនិត្យឡើងវិញលើគ្រប់ពត៌មានហិរញ្ញវត្ថុ និង កិច្ចប្រតិបត្តិការនានា ដើម្បីធានាភាពច្បាស់លាស់ជឿទុកចិត្ត និង ទាន់ពេលវេលា ។
- ពិនិត្យឡើងវិញលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ទ្រព្យសម្បត្តិដែលបានបង្កើត ដើម្បីធានាលើកិច្ចប្រតិបត្តិការឱ្យមានប្រសិទ្ធភាព ។
- ពិនិត្យឡើងវិញលើការគ្រប់គ្រង ថែទាំការពារ និងផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិដែលមានឱ្យបានត្រឹមត្រូវ ។
- ពិនិត្យឡើងវិញលើកម្មវិធីនៃកិច្ចប្រតិបត្តិការគំរោងចំណាយមូលធនដើម្បីធានាបានតាមគោលបំណង និងផែនការដែលបានដាក់ចុះ ។
- ពិនិត្យ និងវាយតម្លៃអំពីប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន និងភាពសន្សំសំចៃ ដើម្បីមានវិធានការកែលំអ ។
- សំរបសំរួលការងារ និងសហប្រតិបត្តិការជាមួយអគ្គាធិការដ្ឋាន អាជ្ញាធរសវនកម្មជាតិ និងស្ថាប័នពាក់ព័ន្ធ ។
- ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវរាយការណ៍ដោយផ្ទាល់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។
- បំពេញកិច្ចការផ្សេងៗទៀត ដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃប្រគល់ឱ្យ ។

**មាត្រា៥ :**

-នាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ ដឹកនាំ និងគ្រប់គ្រងដោយប្រធាន ០១រូប និងអនុប្រធានមួយចំនួនតាមការចាំបាច់ ។

-ចំនួនការិយាល័យនានាចំណុះ នាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ អាស្រ័យដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាអ្នកកំណត់ ។

-ប្រធាន អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាន និងអនុប្រធានការិយាល័យចំណុះត្រូវតែជាមន្ត្រីក្នុងក្របខណ្ឌ ហើយមានសញ្ញាប័ត្រចាប់ពីថ្នាក់ឧត្តមសិក្សា ឬ សញ្ញាប័ត្រសមមូលផ្នែកគណនេយ្យ ឬ ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ មានបទពិសោធន៍ផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ ឬ គ្រប់គ្រងរដ្ឋបាលសាធារណៈ យ៉ាងតិច ៥ឆ្នាំឡើងទៅ ។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា៦ :**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយ នឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៧ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
" ដើម្បីជូនជ្រាប "
-ដូចមាត្រា៧ " ដើម្បីអនុវត្ត "
-ឯកសារ-កាលប្បវត្តិ